ក

មាតិកា

I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៤-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៦៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ ចំពោះ នាយទាហានជាន់ខ្ពស់ ចំនួន ១៤ រូប មានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ ៦៩៦៦

១៤-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៦៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះឯកឧត្ដម HO NGHIA DUNG រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន នៃសាធារណរដ្ឋសង្គមនិយមវៀតណាម មានស្នាដៃល្អ ក្នុងកិច្ចសហប្រតិបត្តិការទ្វេភាគី លើវិស័យសាធារណការ និង ដឹកជញ្ជូនរវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម ៦៩៦៧

១៦-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៦៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះលោក **ជា ឆម៉េង** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានានៅរាជធានីភ្នំពេញ មូលដ្ឋានស្រុកបាណន់ ខេត្តបាត់ដំបង និង ស្រុកមុខកំពូល ខេត្តកណ្ដាល ៦៩៦៨

១៦-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៧០ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូនសពនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ជាកិច្ចបច្ឆាមរណៈ ចំនួន ០៥ រូប ៦៩៦៩

១៦-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៧៣ ស្ដីពី ការតែងតាំងឯកឧត្តម **ឈឹម សៅគី** ជាទីប្រឹក្សាផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៦៩៧០

១៦-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៧៤ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ លោកជំទាវ និង លោក ចំនួន ០២ រូប ដែលបានលះបង់កំលាំងចិត្ត ប្រាជ្ញា ពេលវេលា និង ធនធានយ៉ាងច្រើន បម្រើការងារក្នុងសកម្មភាពមនុស្សធម៌របស់កាកបាទក្រហមកម្ពុជា ៦៩៧១

១៩-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៧៧ ស្ដីពី ការតែងតាំងឯកឧត្តម ចំនួន ០៣ រូប ជាទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានីតិកាលទី ៤ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៦៩៧២

២១-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៧៨ ស្តីពី ការតែងតាំងឯកឧត្តម **ហង់ ថុល** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ ៦៩៧៣

២១-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៧៩ ស្តីពី ការផ្ទេរមុខងារ និង តម្លើងឋានៈ ជូនឯកឧត្តម **ឆាង អ៊ីនធីរ** ពីជំនួយការ មកជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ ៦៩៧៤

២១-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៨៥ ស្តីពី ការផ្ទេរលោក **ឈេង ឈឿឌី** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ទីស្តីការគណៈរដ្ឋមន្ត្រី ៦៩៧៥

២១-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៨៩ ស្តីពី ការតែងតាំងលោក **ម៉ៅ សួន** ជាឧកញ៉ា ៦៩៧៦

២៣-៨-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៨១០/៦៩០ ស្តីពី ការបញ្ចប់មុខតំណែង ឯកឧត្តម **ថាក់ស៊ីន ស៊ីណាវ៉ាត្រា** (THAKSIN SHINAWATRA) ពីទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុកសេដ្ឋកិច្ច តាមសំណើសុំរបស់សាមីខ្លួន ៦៩៧៧

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៨-៨-២០១០ -អនុក្រឹត្យលេខ ១០១ អនក្រ.បក ស្តីពី ការកែសម្រួលការកំណត់របបឧបត្ថម្ភ និង របបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពការងារ ជូនកងយោធពលខេមរភូមិន្ទ និង កងកម្លាំងនគរបាលជាតិ ដែលចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពលី មរណៈ បង្គូស្លាប់ បាត់ខ្លួន និង ពិការ ៦៩៧៨

១៩-៨-២០១០ -អនុក្រឹត្យលេខ ១០២ អនក្រ.បក ស្តីពី ការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០០៩ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៩.៩៩៣ ហិកតា ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្រុករវៀង ខេត្តព្រះវិហារ និង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ៦៩៨១

គ

២០-៨-២០១០ -អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពី ការកំណត់តំបន់សហគមន៍ នៃតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព លើផ្ទៃដីសរុបទំហំ ៣.៩៥៥ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និង ខេត្តសៀមរាប ៦៩៨៣

១៨-៨-២០១០ -អនុក្រឹត្យលេខ ៨៧៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៩៨៦

១៨-៨-២០១០ -អនុក្រឹត្យលេខ ៨៧៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៩៨៧

១៨-៨-២០១០ -អនុក្រឹត្យលេខ ៨៨០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៩៨៨

១៨-៨-២០១០ -អនុក្រឹត្យលេខ ៨៨១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៩៨៩

១៨-៨-២០១០ -អនុក្រឹត្យលេខ ៨៨២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៩៩០

១៨-៨-២០១០ -អនុក្រឹត្យលេខ ៨៨៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៩៩១

១៨-៨-២០១០ -អនុក្រឹត្យលេខ ៨៨៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៩៩២

១៨-៨-២០១០ -អនុក្រឹត្យលេខ ៨៨៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៩៩៣

១៨-៨-២០១០ -អនុក្រឹត្យលេខ ៨៨៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៩៩៤

១៨-៨-២០១០ -អនុក្រឹត្យលេខ ៨៨៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៩៩៥

១៨-៨-២០១០ -អនុក្រឹត្យលេខ ៨៨៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៩៩៦

១៨-៨-២០១០ -អនុក្រឹត្យលេខ ៨៨៩ អនក្រ.តត ស្តីពី ការសម្រួលភារកិច្ចមន្ត្រីរាជការ ៦៩៩៧

១៩-៨-២០១០ -អនុក្រឹត្យលេខ ៨៩០ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៩៩៨

២០-៨-២០១០ -អនុក្រឹត្យលេខ ៨៩១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៧០២៤

២០-៨-២០១០ -អនុក្រឹត្យលេខ ៨៩២ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៧០២៦

២៣-៨-២០១០ -អនុក្រឹត្យលេខ ៨៩៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៧០២៧

២៣-៨-២០១០ -អនុក្រឹត្យលេខ ៨៩៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧០២៨

២៣-៨-២០១០ -អនុក្រឹត្យលេខ ៨៩៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៧០២៩

២៣-៨-២០១០ -អនុក្រឹត្យលេខ ៨៩៦ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យកុមារជាតិ ៧០៣០

III. ការងារបណ្តាក្រសួង

១. ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការពារជាតិ និង ក្រសួងសុខាភិបាល

១០-៨-២០១០ -ប្រកាសរួមលេខ ០៤២/២០១០ ប្រក - លេខ ០៥១ អបស.មព ស្តីពី លក្ខខណ្ឌកាយសម្បទា និង សុខភាពប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធា ៧០៣២

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

១៨-៨-២០១០ -ប្រកាសលេខ ៥៤៤ ប្រក.កសក ស្តីពី ការធ្វើវិញ្ញាបនកម្មច្បារពូជកៅស៊ូ និង ការធ្វើអាជីវកម្មរុក្ខសម្ភារកៅស៊ូ ៧០៤៦

៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៧-១២-២០០៩ -លិខិតបញ្ជាក់លេខ ៤៧៨៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ សម្បត្តិ ត្រេឌីង (កម្ពុជា)** ៧០៥៦

០៧-១២-២០០៩ -លិខិតបញ្ជាក់លេខ ៤៧៩០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាស្ទ័រ ខេម យូមេន រីសសស៍** ៧០៥៨

០៧-១២-២០០៩ -លិខិតបញ្ជាក់លេខ ៤៧៩១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីអេហ្វស៊ី យ៉ែគីថល (ខេមបូឌា)** ៧០៦០

០៧-១២-២០០៩ -លិខិតបញ្ជាក់លេខ ៤៧៩៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិនធើណេសិនណល រ៉ាយស៍ ត្រេឌីង (ខេមបូឌា)** ៧០៦២

០៧-១២-២០០៩ -លិខិតបញ្ជាក់លេខ ៤៧៩៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្រេង យេង អ៊ីមផត អិចផត** ៧០៦៤

០៨-១២-២០០៩ -លិខិតបញ្ជាក់លេខ ៤៨២១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីអូង៉ាដ ថៅអ៊ីរ (ខេមបូឌា) ខូ អិលធីឌី** ៧០៦៦

០៨-១២-២០០៩ -លិខិតបញ្ជាក់លេខ ៤៨២២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យើង ខបភើរេសិន** ៧០៦៨

០៨-១២-២០០៩ -លិខិតបញ្ជាក់លេខ ៤៨២៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីហ្វា លីមីធីត** ៧០៧០

០៩-១២-២០០៩ -លិខិតបញ្ជាក់លេខ ៤៨៣០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោល ហ្វាយនែនសល គ្លូបឹល** ៧០៧២

០៩-១២-២០០៩ -លិខិតបញ្ជាក់លេខ ៤៨៣១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច អ ភី ត្រេនស្ព័រទេសិន** ៧០៧៤

០៩-១២-២០០៩ -លិខិតបញ្ជាក់លេខ ៤៨៣២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេឌា ខលឈ័រ សឺទីស ឌីអិន** ៧០៧៦

១១-១២-២០០៩-លិខិតបញ្ជាក់លេខ ៤៨៣៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភ្នំពេញ ឌីហ្គា ថេគណូឡូជី គ្រុប** ៧០៧៨

ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

នាយទាហានជាន់ខ្ពស់ ចំនួន ១៤ រូប មានស្នាដៃល្អ
និងគុណបំណាច់ខ្ពស់ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ

នូវ

គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ

១	ឧត្តមសេនីយ៍ឯក	ម៉ែន	ឆិចិត្រ	០០០១០៧	៨	ឧត្តមសេនីយ៍ទោ	សេខ	សារី	០០០០៩៨
២	ឧត្តមសេនីយ៍ទោ	ចោង	ប្រាសាទ	០០០៤១៧	៩	ឧត្តមសេនីយ៍ទោ	ម៉ៅ	ឆែន	០០០១១៧
៣	ឧត្តមសេនីយ៍ទោ	សុខ	ឈាន	០០៣៨១៥	១០	ឧត្តមសេនីយ៍ទោ	ម៉ាត់	ជាឡា	០០០៤៣៩
៤	ឧត្តមសេនីយ៍ទោ	អ៊ិន	ហឿន	០០៤៣៥២	១១	ឧត្តមសេនីយ៍ទោ	ពៅ	ស៊ីថា	០០០៣២៧
៥	ឧត្តមសេនីយ៍ទោ	ប៉ែន	សារ៉ែត	០០០៣៩៥	១២	ឧត្តមសេនីយ៍ទោ	ពៅ	សុខា	០០០៤៩៩
៦	ឧត្តមសេនីយ៍ទោ	ព្រហ្ម	មរណៈ	០០០១៥៤	១៣	ឧត្តមសេនីយ៍ទោ	ចាប	ខ៉ានី	០០០២៨៧
៧	ឧត្តមសេនីយ៍ទោ	ចាន់	រ៉ា	០០០៣៤១	១៤	ឧត្តមសេនីយ៍ត្រី	សួន	ខាំឡូ	០០២៦០៨

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ:៦០១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

៣៧.១០០៤.៦៨២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០

ឈិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

ឯកឧត្តម HO NGHIA DUNG

រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូន នៃសាធារណរដ្ឋសង្គមនិយមវៀតណាម មានស្នាដៃល្អ ក្នុងកិច្ច
សហប្រតិបត្តិការទ្វេភាគី លើវិស័យសាធារណការ និងដឹកជញ្ជូន រវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រ៧.២០០៩.៦៩៣

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១០

លេខៈ ៧០៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ទ្រង់ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ

លោក **ជា ឆម៉េង**

ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា
នៅរាជធានីភ្នំពេញ មូលដ្ឋានស្រុកបាណន់ ខេត្តបាត់ដំបង និងស្រុកមុខកំពូល ខេត្តកណ្តាល

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល. ១០០៩. ៦៩៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០

លេខ: ៦០៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានដំឡើងឋានន្តរស័ក្តិ ថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនសពនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ជាកិច្ចបច្ឆាមរណៈ

១- វរសេនីយ៍ឯក	**ឡៀច**	**សុខ**	អត្តលេខ ០០១៣៨៣
២- វរសេនីយ៍ឯក	**នុត**	**ផូរ**	អត្តលេខ ០០២០៩៨
៣- វរសេនីយ៍ឯក	**ហ៊ឺ**	**សារ៉ែន**	អត្តលេខ ០០២៩៧១
៤- វរសេនីយ៍ឯក	**ហ៊ាង**	**សាគួន**	អត្តលេខ ០០២៩៧៣
៥- វរសេនីយ៍ឯក	**ម៉ាន់**	**ចាន់ដារ៉ាវិទ្ធ**	អត្តលេខ ០០៩០៤០

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពរល. ១០០៩. ៦៩៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០

លេខ: ៦០៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចាន់ថុល

នស/រកត/០៨១០/៦៧៣

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ឈឹម សៅរី** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០

ព.រ.ល.១០០៧.៦៩៩

លេខៈ ៦០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
យ៉ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ

លោកជំទាវ ផ្លេក ភីរុណ

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ

លោក គាំង សារឿន

ដែលបានលះបង់កំលាំងកាយចិត្ត ប្រាជ្ញា ពេលវេលា និងធនធានយ៉ាងច្រើន
បម្រើការងារក្នុងសកម្មភាពមនុស្សធម៌របស់កាកបាទក្រហមកម្ពុជា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១០០៩.៦៩៩

លេខៈ ៧១០ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ សីហា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

<u>មាត្រា១</u> : ត្រូវបានតែងតាំង :

១- **ឯកឧត្តម អ៊ឹង ម៉ារ៉ាឌី** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- **ឯកឧត្តម ឈុំ សាឡឿន** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

៣- **ឯកឧត្តម សុខ ព្រេះ** ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

<u>មាត្រា២</u> : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

<u>មាត្រា៣</u> : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.១០០៩.៦៩២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០

លេខៈ ៦១៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្តម **ឃាង ថុល** ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.១០០៧.៦៩៣

លេខ:៦៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ សីហា ឆ្នាំ២០១០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្ទេរមុខងារ និងតម្លើងឋានៈជូនឯកឧត្តម **ឆាយ ឫទ្ធិសែន** ពីជំនួយការ មកជាទីប្រឹក្សា សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ១០០៧. ៦៩៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១០

លេខៈ ៦១៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរ លោក **ហេង ហ៊ើរឌី** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១០០៩.៧០០

លេខៈ ៦៥៤ ច.ល
[illegible] ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១០

[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៨១០/៦៧៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

លោក ង៉ោ សួន

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៧៧.១០០៧.៧០៤

នរោត្តម សីហមុនី

លេខៈ ៦៧៣ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១០ [illegible] ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ សីហា ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនកេន

នស/រកត/០៨១០/៦៩០

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/១០០៩/១០១៨ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៩ ស្តីពីការតែងតាំងឯកឧត្តម ថាក់ស៊ីន ស៊ីណាវ៉ាត្រា ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាទីប្រឹក្សារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទទួលបន្ទុកសេដ្ឋកិច្ច
- បានទ្រង់យល់សំណើសុំរបស់ ឯកឧត្តម ថាក់ស៊ីន ស៊ីណាវ៉ាត្រា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ៖ ត្រូវបានបញ្ចប់មុខតំណែង ឯកឧត្តម **ថាក់ស៊ីន ស៊ីណាវ៉ាត្រា** (THAKSIN SHINAWATRA) ពីទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាទីប្រឹក្សារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទទួលបន្ទុកសេដ្ឋកិច្ច តាមសំណើសុំរបស់សាមីខ្លួន ។

មាត្រា ២ ៖ បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ ៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១០០៩.៧០៥

លេខ ៦១៨ ច.ល
ចំលងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១០
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១០

ស៊ុំ ម៉ានិត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១០១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលការកំណត់របបឧបត្ថម្ភ និងរបបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពការងារ ជូនកងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ ដែលចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពលី មរណៈ បន្ទុកស្លាប់ បាត់ខ្លួន និង ពិការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៧ នស.៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិន នៃកង យោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍ និង សោធនបាត់បង់ សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីរបបឧបត្ថម្ភគោលនយោបាយ ចំពោះមន្ត្រីនគរបាល ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ
- យោងតាមការចាំបាច់

សម្រេច

មាត្រា ១-

អនុក្រឹត្យនេះ មានគោលដៅកែសម្រួលការកំណត់របបឧបត្ថម្ភ និងរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ជូនកងយោធពលខេមរភូមិន្ទ និង កងកម្លាំងនគរបាលជាតិ ដែលចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ ។

មាត្រា ២-

ប្រាក់ឧបត្ថម្ភលើកដំបូងម្តងគត់ ជូនកងយោធពលខេមរភូមិន្ទ និងកងកំលាំងនគរបាលជាតិ ដែលចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ ដែលបានកំណត់នៅក្នុងអនុក្រឹត្យ ឬ បទបញ្ញត្តិទាំងឡាយពាក់ព័ន្ធនឹងរបបឧបត្ថម្ភដោយផ្អែកលើប្រាក់បៀវត្សចុងក្រោយ ឬ ប្រាក់បៀវត្សសរុបចុងក្រោយ ត្រូវបានកែសម្រួលមកជារបបឧបត្ថម្ភដោយផ្អែកលើប្រាក់បៀវត្សមូលដ្ឋានចុងក្រោយវិញ ។

មាត្រា ៣-

ប្រាក់សោធននិវត្តន៍ និងប្រាក់សោធនបាត់បង់សមត្ថភាពការងារ ជូនយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ដូចមានចែងក្នុងមាត្រា ៨ នៃជំពូកទី ២ និងមាត្រា ១៤ នៃជំពូកទី ៣ នៃអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ត្រូវបានកែសម្រួលមកជាប្រាក់សោធននិវត្តន៍ និងប្រាក់សោធនបាត់បង់សមត្ថភាពការងារ ដែលមានតែប្រាក់បៀវត្សមូលដ្ឋានចុងក្រោយប៉ុណ្ណោះ ។

មាត្រា ៤-

អនុក្រឹត្យនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១០ ។

មាត្រា ៥-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ៧ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០៧ . អនុក្រ. បក

អនុក្រឹត្យ

ស្តីពី

ការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០០៩ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៩.៩៩៣ហិកតា ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្រុករវៀង ខេត្តព្រះវិហារ និងស្រុកសណ្តាន់ ខេត្តកំពង់ធំ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធី នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៩៩៩៣ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្រុករវៀង ខេត្តព្រះវិហារ និងស្រុកសណ្តាន់ ខេត្តកំពង់ធំ
- បានឃើញអនុក្រឹត្យលេខ ១២៨ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៩ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០១០ ស្តីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១២៨ អនក្រ.បក ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០៩ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល។

សម្រេច

មាត្រា១៖

ត្រូវធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០០៩ ត្រង់មាត្រា១ នៅឃ្លាចុងក្រោយត្រូវបានកែសម្រួលពី «ដូចមានក្នុងផែនទី និងនិយាមកា ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ៦ នៃលិខិតលេខ ១៩៥០ សណ.បស្ត.អកជ ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០០៩ របស់ក្រសួងបរិស្ថានជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ» មកជា: «ដូចមានក្នុងផែនទី និងនិយាមកា ជាឯកសារភ្ជាប់នឹងលិខិតលេខ ៨៤១ សជណ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ» វិញ ដែលមានខ្លឹមសារនៃមាត្រា១ ដូចខាងក្រោមៈ

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៩.៩៩៣ហិកតា ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្រុករវៀង ខេត្តព្រះវិហារ និងស្រុកសណ្តាន់ ខេត្តកំពង់ធំ ក្រោមល័ក្ខខ័ណ្ឌជួល ឬសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើការដាំដំណាំកៅស៊ូ និងប្រភេទឈើផ្សេងៗទៀត ដូចមានក្នុងផែនទី និងនិយាមកា ជាឯកសារភ្ជាប់នឹងលិខិតលេខ ៨៤១ សជណ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២៖

ខ្លឹមសារនៃមាត្រាដទៃផ្សេងទៀត របស់អនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០០៩ នៅតែមានសុពលភាពជាគតិយុត្តដដែល។

មាត្រា៣៖

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកំណត់តំបន់សហគមន៍ នៃតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព លើផ្ទៃដីសរុបទំហំ ៣៩៩៩ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី តំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា១:-

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព លើផ្ទៃដីសរុប **បីពាន់ប្រាំបួនរយកៅសិបប្រាំបួន** (៣៩៩៩) ហិកតា ទៅជា **តំបន់សហគមន៍** ចំនួនបីតំបន់ដែលមានភូមិសាស្ត្រស្ថិតនៅក្នុងខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប ដូចមានក្នុងផែនទីភ្ជាប់មកជាមួយ និងនិយាមកាដូចខាងក្រោម:

១. តំបន់ឈូក និងតែល ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ លើផ្ទៃដី ១៣៩៥ ហិកតា								
ID	X	Y	ID	X	Y	ID	X	Y
1	438399	1543064	4	442062	1541962	7	438511	1540585
2	439136	1542945	5	442025	1538702	8	437968	1540801
3	439278	1542014	6	438077	1538755			

២.ភូមិជើងពានមាស ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ លើផ្ទៃដី ១៣៨៦ ហិកតា								
1	437102	1541188	6	438370	1543101	11	436505	1543169
2	437228	1540406	7	438592	1544824	12	435471	1542646
3	437662	1540311	8	437620	1547381	13	436630	1541754
4	438119	1541751	9	435499	1546707			
5	437736	1542604	10	435669	1544263			
៣. ភូមិក្រមុំបួល ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប លើផ្ទៃដី ១២១៨ ហិកតា								
1	433460	1533881	5	437957	1540580	9	437477	1535352
2	434280	1536530	6	438454	1540503	10	435754	1535615
3	434677	1536366	7	438062	1538751	11	434577	1533318
4	436392	1539381	8	436466	1537453			

មាត្រា២ –

ការកំណត់ **តំបន់សហគមន៍** ស្ថិតនៅក្នុងតំបន់ទាំងបី ដែលមានភូមិសាស្ត្រស្ថិតនៅក្នុងខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប ដូចមាននិយាមកាខាងលើនេះ គឺជាតំបន់គ្រប់គ្រងបម្រើឱ្យការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍មូលដ្ឋានរួមមានៈ លំនៅដ្ឋាន ស្រែ ចំការ ។ រាល់ការចេញប័ណ្ណសំគាល់កម្មសិទ្ធិ កាន់កាប់ដីធ្លី ឬ ការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់សហគមន៍នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល ។

មាត្រា៣ –

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤ –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តព្រះវិហារ ឧត្តរមានជ័យ សៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ផែនទី កំណត់តំបន់សហគមន៍ នៃដែនជម្រកសត្វព្រៃ គូលែន-ព្រហ្មទេព

លើផ្ទៃដីសរុបទំហំ ៣៩៩៩ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប

អនុក្រឹត្យ លេខៈ ១០៣ អនក្រ.បក

ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១០





សញ្ញាសំគាល់

- ● ចំណុចនិយាមកា
- តំបន់សហគមន៍ ផ្ទៃដីទំហំ ១៣៩៥ ហិកតា ខេត្តព្រះវិហារ
- តំបន់សហគមន៍ ផ្ទៃដីទំហំ ១៣៨៦ ហិកតា ខេត្តឧត្តរមានជ័យ
- តំបន់សហគមន៍ ផ្ទៃដីទំហំ ១២១៨ ហិកតា ខេត្តសៀមរាប

ID	X	Y	ID	X	Y	ID	X	Y
១ តំបន់សហគមន៍ [illegible] ឃុំ [illegible] ស្រុក [illegible] ខេត្តព្រះវិហារ ផ្ទៃដី ១៣៩៥ ហិកតា								
1	438399	1543064	4	442062	1541962	7	438511	1540565
2	439136	1542945	5	442025	1538702	8	437968	1540801
3	439278	1542014	6	438077	1538755			
២ ភូមិ [illegible] ឃុំ [illegible] ស្រុក [illegible] ខេត្តឧត្តរមានជ័យ ផ្ទៃដី ១៣៨៦ ហិកតា								
1	437102	1541188	6	438370	1543101	11	436505	1543169
2	437228	1540406	7	438592	1544824	12	435471	1542648
3	437662	1540311	8	437620	1547381	13	436630	1541754
4	438119	1541751	9	435499	1546707			
5	437736	1542604	10	435669	154426[illegible]			
៣ ភូមិ [illegible] ឃុំ [illegible] ស្រុក [illegible] ខេត្តសៀមរាប ផ្ទៃដី [illegible]								
1	433460	1533881	5	437957	[illegible]	9	437477	[illegible]
2	434280	1536530	6	438454	[illegible]	10	[illegible]	[illegible]
3	434677	1536366	7	438062	[illegible]	[illegible]	434577	[illegible]
4	436392	1539381	8	436466	[illegible]	[illegible]	[illegible]	[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៧៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានផ្តល់ថវិកាសរុប ចំនួន ១៤០.០០០ ដុល្លារអាមេរិក តាមរយៈអង្គការ SCHOOL AID JAPAN ក្នុងការជួយកសាងអគារសិក្សា និងបង្គន់អនាម័យ ជូនដល់អនុវិទ្យាល័យវត្តតាមឹម ស្ថិតនៅក្នុងឃុំតាមឹម ស្រុកសង្កែ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :-

១-**H.E. SHINOHARA KATSUHIRO** ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា បានជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៦បន្ទប់ និងបង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ ។

២-**Mr. WATANABE MIKI** អគ្គនាយកអង្គការ SCHOOL AID JAPAN បានជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៦បន្ទប់ ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន Mr. KANAMURA HIROYOSHI ដែលបានផ្តល់ថវិកាចំនួន ៣១.០០០ ដុល្លារអាមេរិក តាមរយៈសមាគមជំនួយខ្មែរ សតវត្សទី២១ ក្នុងការជួយកសាង អគារសិក្សាចំនួន០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់បរិក្ខារគ្រប់គ្រាន់ និងបង្គន់អនាម័យ ០១ខ្នង មាន០២បន្ទប់ ជូនដល់សាលាបឋមសិក្សាគិរីសុខុម ស្ថិតនៅឃុំទំព័រមាស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤០ . អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០៣គ្រឿង ជូនសប្បុរសជន ដែលបានផ្តល់ថវិកាសរុប ចំនួន ១១៨.១៨៤ ដុល្លារអាមេរិក តាមរយៈអង្គការ JHP ក្នុងការជួយកសាងអគារស្នាក់នៅ ចំនួន០១ខ្នង កម្ពស់០២ជាន់ មាន១២បន្ទប់ បង្គន់អនាម័យ ០១ ខ្នង មាន ០៨ បន្ទប់ ព្រមទាំងបំពាក់គ្រឿងបរិក្ខារគ្រប់គ្រាន់ ជូនដល់សាលាគរុកោសល្យ និងវិក្រឹតការខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម :-

១-លោកស្រី **Osanai Mieko** ប្រធានអង្គការ JHP ជប៉ុន

២-**Ms. Nagami Michiko** សប្បុរសជនជប៉ុន

៣-**All Participants in Japan's Postal Savings for International Voluntary Aid**

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៤១ . អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនព្រះតេជគុណ HAYASAKA BUNMEI ព្រះចៅអធិការវត្ត TOKUHON-JI Temple ដែលបានផ្តល់ថវិកាចំនួន ៣៤.៥០៤.៣៩ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់បរិក្ខារគ្រប់គ្រាន់ ធ្វើខ្លោងទ្វារ ដងទង់ជាតិ បង្គន់អនាម័យ ០៤បន្ទប់ និងអណ្តូងទឹក០១ ជូនដល់សាលាបឋមសិក្សាដុបត្នោត ស្ថិតនៅឃុំពង្រលើ ស្រុកជីក្រែង ខេត្តសៀមរាប ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ៧ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៩៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគម SOTOSHU TOCHI GIKEN INTERNATIONAL VOLUNTEER ASSOCIATION ដែលបានផ្តល់ថវិកា ចំនួន ៦២.០៤៨,០៥ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់សម្ភារៈបរិក្ខារគ្រប់គ្រាន់ ធ្វើខ្លោងទ្វារ ដងទង់ជាតិ បង្គន់អនាម័យ ០៤បន្ទប់ អាងទឹក០១ ស្រះទឹក០១ និង ផ្ទះសំណាក់គ្រូ ០១ខ្នង ជូនដល់សាលាបឋមសិក្សា ខ្នាផ្តៅល ស្ថិតនៅឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជន ចំនួន០៣រូប ដែលបានផ្តល់ថវិកាសរុបចំនួន ៤២.៧៥០ ដុល្លារអាមេរិក តាមរយៈអង្គការ ASAC ក្នុងការកសាងអគារសិក្សា ចំនួន០១ខ្នង មាន០៣បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ ធ្វើខ្លោងទ្វារ បង្គន់អនាម័យចំនួន០១ខ្នង មាន០២ បន្ទប់ និងអណ្តូងទឹក ជូនដល់សាលាបឋមសិក្សាមិត្តភាព ហ្វាលល្បៀ ឈូក ស្ថិតនៅក្នុងឃុំគោករវៀង ស្រុកជើងព្រៃ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមាសស្ថាបនាជាតិ :

១-Mr.. KAWACHI HIROSHI អគ្គនាយកក្រុមហ៊ុន ហ្វាលល្បៀ

២-Mr.. SHIGENORY OKAMORA ប្រធានអង្គការ ASAC

ខ.មេដាយប្រាក់ស្ថាបនាជាតិ :

-លោក **តែម ផាត** សប្បុរសជន បានឧបត្ថម្ភដីស្រែសំរាប់សាងសង់សាលារៀន គិតជាទឹកប្រាក់មានតម្លៃស្មើ ៦.០៥០ ដុល្លារអាមេរិក ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

១០១-នាយចំណង់	សុខ ជា	អត្តលេខ ០៦៤៥៤២	បុ.បំរើការ គិលានដ្ឋាន
			កងពលធំអន្តរាគមន៍លេខ២
១០២-នាយចំណង់	ចៅ ឃុំ	អត្តលេខ ១០២៧៥១	ជំ.បុគ្គលិក វ.តូចដឹកជញ្ជូន
			កងពលធំអន្តរាគមន៍លេខ២
១០៣-នាយចំណង់	អ៊ុន សុផុល	អត្តលេខ ១៥៦៦៧៣	ជំ.បុគ្គលិក វ.តូចដឹកជញ្ជូន
			កងពលធំអន្តរាគមន៍លេខ២
១០៤-នាយចំណង់	ឈុំ គាន	អត្តលេខ ១០២៦៣២	មេអ.តូច១ អ.ធំ១ វ.តូចដឹកជញ្ជូន
			កងពលធំអន្តរាគមន៍លេខ២
១០៥-នាយចំណង់	ប៉ាច ជន	អត្តលេខ ១០២៦៣៣	មេអ.តូច២ អ.ធំ១ វ.តូចដឹកជញ្ជូន
			កងពលធំអន្តរាគមន៍លេខ២
១០៦-នាយចំណង់	ចាន់ សុខុម	អត្តលេខ ១០៣២៨៦	មេអ.តូច៣ អ.ធំ១ វ.តូចដឹកជញ្ជូន
			កងពលធំអន្តរាគមន៍លេខ២
១០៧-នាយចំណង់	ចម ម៉ៅ	អត្តលេខ ១០២៦៨៧	មេអ.តូច១ អ.ធំ២ វ.តូចដឹកជញ្ជូន
			កងពលធំអន្តរាគមន៍លេខ២
១០៨-នាយចំណង់	ពី គ្លូ	អត្តលេខ ១០៣៨៣១	មេអ.តូច៣ អ.ធំ២ វ.តូចដឹកជញ្ជូន
			កងពលធំអន្តរាគមន៍លេខ២
១០៩-នាយចំណង់	ធិន ធួត	អត្តលេខ ០៦៨៧៥៧	មេរងអ.តូច៣ អ.ធំ២ វ.តូចដឹកជញ្ជូន
			កងពលធំអន្តរាគមន៍លេខ២
១១០-នាយចំណង់	តែម ឡាម	អត្តលេខ ១០២២៧៧	មេអ.តូច១ អ.ធំ៣ វ.តូចដឹកជញ្ជូន

កងពលធំអន្តរាគមន៍លេខ២

១១១-នាយចំណង់ ព្រុំ សារុន អត្តលេខ ០៦៨៥៦១ មេអ.តូច២ អ.ធំ៣ វ.តូចដឹកជញ្ជូន
កងពលធំអន្តរាគមន៍លេខ២

១១២-នាយចំណង់ គុជ ចាន់ អត្តលេខ ០៦៨៥៦៣ មេរងអ.តូច២ អ.ធំ៣ វ.តូចដឹកជញ្ជូន
កងពលធំអន្តរាគមន៍លេខ២

១១៣-នាយចំណង់ សូ សុគ័ន្រ អត្តលេខ ០៥០៥៩២ ជ.ប្រតិបត្តិការសឹក វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១១៤-នាយចំណង់ នន់ សុទិដ្ឋិភា អត្តលេខ ០៥៩៨៧៣ ជំ.បញ្ជូនសារ វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១១៥-នាយចំណង់ ចាន់ ចំាវុទ្ធ អត្តលេខ ០៥០៥៧៩ ជំ.ស៊ើបការណ៍ វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១១៦-នាយចំណង់ ជុំ សារឿន អត្តលេខ ០៥០៦០០ ជំ.បញ្ជូនសារ វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១១៧-នាយចំណង់ ឈឹម សាវុឌ អត្តលេខ ០៨៩១៥៤ ជំ.ធានា វ.តូច វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១១៨-នាយចំណង់ ស៊ុខ សុខណ្ណារ៉េត អត្តលេខ ០៦៩៨៩៦ មេ ខដឹកជញ្ជូន វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១១៩-នាយចំណង់ ម៉ៀខ អ៊ុំ អត្តលេខ ០៥៩៩៣៥ មេរង ខដឹកជញ្ជូន វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១២០-នាយចំណង់ មាន តេនា អត្តលេខ ០៧៩៦៩៣ មេរង ខដឹកជញ្ជូន វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១២១-នាយចំណង់ មួយ ភាន អត្តលេខ ០៥៩៩៣២ មេអ.តូចជួសជុល វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១២២-នាយចំណង់ ពៅ នួច អត្តលេខ ០៦៩៨៨៩ មេអ.តូចគាំទ្រ វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១២៣-នាយចំណង់ នួន នុយ អត្តលេខ ០៦៩៨៩២ មេរងអ.តូចគាំទ្រ វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១២៤-នាយចំណង់ ខ៉ែត ឡឿន អត្តលេខ ០៦៩៩០៩ មេ អ.តូច១ អ.ធំ ១ វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១២៥-នាយចំណង់ លឹម នាយ អត្តលេខ ០៥៩៩៣៤ មេ អ.តូច២ អ.ធំ ១ វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១២៦-នាយចំណង់ សូ សុផានី អត្តលេខ ០៥៩៩២៥ មេ អ.តូច៣ អ.ធំ ២ វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១២៧-នាយចំណង់ ឌី ចំរើន អត្តលេខ ០៦៩៨៩០ មេរងអ.តូច៣ អ.ធំ ២ វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១២៨-នាយចំណង់ សេខ ផាន អត្តលេខ ០៧៩៧១១ មេ អ.តូច៤ អ.ធំ២ វ.តូចរថក្រោះ
កងពលធំអន្តរាគមន៍លេខ២

១២៩-នាយចំណង់ គា គឿន អត្តលេខ ០៧៩៧០៩ មេ អ.តូច៥ អ.ធំ ២ វ.តូចរថក្រោះ

កងពលធំអន្តរាគមន៍លេខ២

១៣០-នាយចំណាង់ មុត អឿន អត្តលេខ ០៦៩៩៣២ មេ អ.តូច៦ អ.ធំ២ វ.តូចរថក្រោះ

កងពលធំអន្តរាគមន៍លេខ២

១៣១-នាយចំណាង់ ជៀប វ៉ែត អត្តលេខ ០៨៩១២៨ មេ អ.តូច៧ អ.ធំ ៣ វ.តូចរថក្រោះ

កងពលធំអន្តរាគមន៍លេខ២

១៣២-នាយចំណាង់ ម៉ម ឡឿន អត្តលេខ ០៥៩៩៣១ មេ អ.តូច៨ អ.ធំ ៣ វ.តូចរថក្រោះ

កងពលធំអន្តរាគមន៍លេខ២

១៣៣-នាយចំណាង់ សៀង សេង អត្តលេខ ០៥០៥៩៦ មេរង អ.តូច៨ អ.ធំ៣ វ.តូចរថក្រោះ

កងពលធំអន្តរាគមន៍លេខ២

១៣៤-នាយចំណាង់ នាំ នេត អត្តលេខ ១០១៦៨១ មេ អ.តូច៩ អ.ធំ ៣ វ.តូចរថក្រោះ

កងពលធំអន្តរាគមន៍លេខ២

១៣៥-នាយចំណាង់ ទូច នឿន អត្តលេខ ០៧៩៧១៦ មេរងអ.តូច៩ អ.ធំ ៣ វ.តូចរថក្រោះ

កងពលធំអន្តរាគមន៍លេខ២

១៣៦-នាយចំណាង់ ស៊ត់ ម៉អ់ អត្តលេខ ១៥៦៨៥៣ ជ.ផ្នែកបច្ចេកទេស

កងពលតូចអន្តរាគមន៍លេខ៤

១៣៧-នាយចំណាង់ ឈួន ទុន អត្តលេខ ០៧០៨៥១ ជំ.ការិយាល័យទី១

កងពលតូចអន្តរាគមន៍លេខ៤

១៣៨-នាយចំណាង់ សុគ្រ សុទ្ធ អត្តលេខ ១៥៦៨៩៧ ជំ.ការិយាល័យទី២

កងពលតូចអន្តរាគមន៍លេខ៤

១៣៩-នាយចំណាង់ ព្រិល វណ្ណា: អត្តលេខ ១០២៩៩៥ ជំ.ការិយាល័យទី៣

កងពលតូចអន្តរាគមន៍លេខ៤

១៤០-នាយចំណាង់ នេង វៃ អត្តលេខ ០៦៤៧១៦ ជំ.ការិយាល័យទី៣

កងពលតូចអន្តរាគមន៍លេខ៤

១៤១-នាយចំណាង់ អោម សុតិន អត្តលេខ ០៧០៩១១ ជំ.ការិយាល័យទី៤

កងពលតូចអន្តរាគមន៍លេខ៤

១៤២-នាយចំណាង់ ពឿន ជឿន អត្តលេខ ១០២៨៤០ ជំ.ការិយាល័យទី៤

កងពលតូចអន្តរាគមន៍លេខ៤

១៤៣-នាយចំណាង់ ស៊ុត ដន អត្តលេខ ១៥៦៨៩៨ ជំ.ការិយាល័យទី៤

កងពលតូចអន្តរាគមន៍លេខ៤

១៤៤-នាយចំណាង់ វន្យ ឈឿន អត្តលេខ ១៥៦៩០១ មេអ.តូច១ អ.ធំស៊ើបការ

កងពលតូចអន្តរាគមន៍លេខ៤

១៤៥-នាយចំណាង់ លាង ហៀប អត្តលេខ ០៦៤៥៦៥ មេអ.តូច១ អ.ធំដឹកជញ្ជូន

កងពលតូចអន្តរាគមន៍លេខ៤

១៤៦-នាយចំណាង់ ដួច សាហាន អត្តលេខ ១៥៦៨១៦ មេអ.តូច១ អ.ធំកាំភ្លើងធំ

កងពលតូចអន្តរាគមន៍លេខ៤

១៤៧-នាយចំណាង់ កែវ ចាន់ អត្តលេខ ១៥៦៧៩៤ មេអ.តូច២ អ.ធំបញ្ជូនសារ

កងពលតូចអន្តរាគមន៍លេខ៤

១៤៨-នាយចំណាង់ ដួន សោម អត្តលេខ ០៨១៧០៤ មេអ.តូច១ អ.ធំការពារ

កងពលតូចអន្តរាគមន៍លេខ៤

១៤៩-នាយចំណាង់ ធួន ម៉យ អត្តលេខ ១៥៦៨៦៩ មេអ.តូច២ អ.ធំដឹកជញ្ជូន

កងពលតូចអន្តរាគមន៍លេខ២៤
១៥០-នាយចំណាង ឃួន សាខន អត្តលេខ ០៧០៣៨៧ ជំ.បុគ្គលិក វ.តូច២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៥១-នាយចំណាង ម៉ែត សំបូរ អត្តលេខ ០៧០៤១៨ ជំ.ប្រតិបត្តិការសឹក វ.តូច២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៥២-នាយចំណាង យឹម សារឿម អត្តលេខ ១៥៦៩១៨ ជំ.ពេទ្យ វ.តូច ២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៥៣-នាយចំណាង ឡុង រ៉ា អត្តលេខ ១០៣២០៨ ជំ.ពេទ្យ វ.តូច ២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៥៤-នាយចំណាង ទេព គុម អត្តលេខ ១៥៦៧៨៧ មេ អ.តូចការពារ វ.តូច ២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៥៥-នាយចំណាង សាន់ ឡូច អត្តលេខ ០៧០៦១១ មេរងអ.តូចការពារ វ.តូច២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៥៦-នាយចំណាង ឡើ ឡៀន អត្តលេខ ១៥៦៨៩២ មេអ.តូច១ អ.ធំ១ វ.តូច២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៥៧-នាយចំណាង ញោម ញឿន អត្តលេខ ១៥៦៨៧២ មេរងអ.តូច១ អ.ធំ១ វ.តូច២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៥៨-នាយចំណាង ចៅ ម៉ិនឡេង អត្តលេខ ១៥៦៩៦៧ មេរងអ.តូច១ អ.ធំ១ វ.តូច២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៥៩-នាយចំណាង ធីក ណុច អត្តលេខ ១៥៦៩៣១ មេ អ.តូច២ អ.ធំ១ វ.តូច ២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៦០-នាយចំណាង សាន់ សេន អត្តលេខ ១៥៦៩២៨ មេអ.តូច៣ អ.ធំ១ វ.តូច២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៦១-នាយចំណាង ឡឹម ហឿន អត្តលេខ ០៦៤៦៩១ មេរងអ.តូច១ អ.ធំ៣ វ.តូច២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៦២-នាយចំណាង តាំង តោក អត្តលេខ ១៥៦៨៨២ មេរងអ.តូច១ អ.ធំ៣ វ.តូច២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៦៣-នាយចំណាង ផល សារឿន អត្តលេខ ១៥៦៨៧៥ មេរងអ.តូច២ អ.ធំ៣ វ.តូច២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៦៤-នាយចំណាង គន់ រ៉េត អត្តលេខ ០៦៨៥៩៥ មេរងអ.តូច៣ អ.ធំ៣ វ.តូច២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៦៥-នាយចំណាង ជា សំណាង អត្តលេខ ១៥៧០៣០ មេរង អ.ធំគាំទ្រ វ.តូច ២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៦៦-នាយចំណាង នូ សៅ អត្តលេខ ១៥៦៨៦១ មេអ.តូច៣ អ.ធំគាំទ្រ វ.តូច ២៤១
កងពលតូចអន្តរាគមន៍លេខ២៤
១៦៧-នាយចំណាង ទី យាន អត្តលេខ ១០៤០៦៥ មេអ.តូចត្បាល់៨២មម អ.ធំគាំទ្រ
វ.តូច២៤១ កងពលតូចអន្តរាគមន៍លេខ២៤
១៦៨-នាយចំណាង ឈើយ ឌុង អត្តលេខ ០៦៨៨៨៨ មេរងអ.តូចត្បាល់៨២មម អ.ធំគាំទ្រ
វ.តូច២៤១ កងពលតូចអន្តរាគមន៍លេខ២៤
១៦៩-នាយចំណាង ម៉ិល លីឈន អត្តលេខ ១៥៧០៣៥ មេអ.តូចដេកាហ្សេត អ.ធំគាំទ្រ

វ.តូច២៤១ កងពលតូចអន្តរាគមន៍លេខ៤

១៧០-នាយចំណង់ ញ៉ៅ ឃី អត្តលេខ ០៦៤៨៣១ មេរងអ.តូចដេកាហ្សេត អ.ធំគាំទ្រ
វ.តូច២៤១ កងពលតូចអន្តរាគមន៍លេខ៤

១៧១-នាយចំណង់ ដែទ សារឿន អត្តលេខ ១០៣១០៦ មេអ.តូចការពារ វ.តូច២៤៣
កងពលតូចអន្តរាគមន៍លេខ៤

១៧២-នាយចំណង់ ម៉ី ដួង អត្តលេខ ១៥៦៨៥០ មេអ.តូច១ អ.ធំ១ វ.តូច២៤៣
កងពលតូចអន្តរាគមន៍លេខ៤

១៧៣-នាយចំណង់ ថាន់ លោម អត្តលេខ ១៥៧០២៦ មេអ.តូច១ អ.ធំ២ វ.តូច២៤៣
កងពលតូចអន្តរាគមន៍លេខ៤

១៧៤-នាយចំណង់ កង ផល្លី អត្តលេខ ១០៣០៧៥ មេអ.តូច២ អ.ធំ២ វ.តូច២៤៣
កងពលតូចអន្តរាគមន៍លេខ៤

១៧៥-នាយចំណង់ អ៊ុច គេង អត្តលេខ ១៥៦៨១៣ មេអ.តូច៣ អ.ធំ២ វ.តូច២៤៣
កងពលតូចអន្តរាគមន៍លេខ៤

១៧៦-នាយចំណង់ ឯម ឡើយ អត្តលេខ ១០៣១៦៤ មេអ.តូច១ អ.ធំ៣ វ.តូច២៤៣
កងពលតូចអន្តរាគមន៍លេខ៤

១៧៧-នាយចំណង់ ម៉ែន ឡឹង អត្តលេខ ១០៣១៨៤ មេអ.តូច៣ អ.ធំ៣ វ.តូច២៤៣
កងពលតូចអន្តរាគមន៍លេខ៤

១៧៨-នាយចំណង់ សា គឿន អត្តលេខ ១៥៦៨៥៧ ជំ.លេខាធិការដ្ឋាន
កងពលតូចអន្តរាគមន៍លេខ៥

១៧៩-នាយចំណង់ ស៊ុន ពៅ អត្តលេខ ១៥៦៨៧៤ ជំ.លេខាធិការដ្ឋាន
កងពលតូចអន្តរាគមន៍លេខ៥

១៨០-នាយចំណង់ ព្រហ្ម សារ៉ាច័ន្ទ អត្តលេខ ០៦៤៧៥៦ ជំ.លេខាធិការដ្ឋាន
កងពលតូចអន្តរាគមន៍លេខ៥

១៨១-នាយចំណង់ ឯម សុភាព អត្តលេខ ១០៣៨១៩ ជំ.ការិយាល័យទី ១
កងពលតូចអន្តរាគមន៍លេខ៥

១៨២-នាយចំណង់ ផ្លុង រ៉ែត អត្តលេខ ០៦៤៦៣៩ ជំនួយការ ក៣
កងពលតូចអន្តរាគមន៍លេខ៥

១៨៣-នាយចំណង់ អោក យន អត្តលេខ ០៦៤៨០៣ ជំនួយការ ក៤
កងពលតូចអន្តរាគមន៍លេខ៥

១៨៤-នាយចំណង់ ប្រាក់ ហុង អត្តលេខ ១០៤១៩២ មេរង គ ការពារ
កងពលតូចអន្តរាគមន៍លេខ៥

១៨៥-នាយចំណង់ សោម សាវី អត្តលេខ ០៧០៧០៣ ជំ.ស្បៀង វ.តូច ២៥១
កងពលតូចអន្តរាគមន៍លេខ៥

១៨៦-នាយចំណង់ ពេជ្រ សុគុណា អត្តលេខ ១៥៧០៦៣ ជំ.បុគ្គលិក វ.តូច ២៥១
កងពលតូចអន្តរាគមន៍លេខ៥

១៨៧-នាយចំណង់ ផល ថាន់ស៊ី អត្តលេខ ០៦៤៨០២ មេរង អ.ធំ៣ វ.តូច ២៥១
កងពលតូចអន្តរាគមន៍លេខ៥

១៨៨-នាយចំណង់ សែស ស៊ីង អត្តលេខ ១៥៧០៧៤ ជំ.ស្បៀង វ.តូច ២៥២
កងពលតូចអន្តរាគមន៍លេខ៥

១៨៩-នាយចំណង់ ពេជ្រ សារ៉ែត អត្តលេខ ១០២៧១៦ ជំ.ហិរញ្ញវត្ថុ វ.តូច ២៥២

១៩០-នាយចំណាង	**នោគ ចយ**	អត្តលេខ ១៥៦៩៥៦	កងពលតូចអន្តរាគមន៍លេខ៥ ជំ.ហិរញ្ញវត្ថុ វ.តូច ២៥៣
១៩១-នាយចំណាង	**ម៉ូ រិត**	អត្តលេខ ០៨៦២៧២	កងពលតូចអន្តរាគមន៍លេខ៥ មេរង អ.ធំ១ វ.តូច ២៥៤
១៩២-នាយចំណាង	**សែម សាហាន**	អត្តលេខ ១៥៦៦៤៥	កងពលតូចអន្តរាគមន៍លេខ៥ នាយរងការិយាល័យទី៤
១៩៣-នាយចំណាង	**សុខ ឧុទ្ធី**	អត្តលេខ ១០២០៤២	កងពលតូចអន្តរាគមន៍លេខ៦ ជំ.ឃ្លាំង ការិយាល័យទី៤
១៩៤-នាយចំណាង	**ឃុត ឃឿត**	អត្តលេខ ០៧០៨៤៨	កងពលតូចអន្តរាគមន៍លេខ៦ ជំ.ភស្តុភារ បច្ចេកទេស
១៩៥-នាយចំណាង	**អ៊ា តាន**	អត្តលេខ ០៦៤៤៨១	កងពលតូចអន្តរាគមន៍លេខ៦ នាយផ្នែកបញ្ជូនសារ
១៩៦-នាយចំណាង	**ហោខ ឧុទ្ធី**	អត្តលេខ ១៥៦៩៤២	កងពលតូចអន្តរាគមន៍លេខ៦ មេរង អ.ធំស៊ើបការណ៍
១៩៧-នាយចំណាង	**ឃិន អ៊ាត**	អត្តលេខ ០៦៨០០២	កងពលតូចអន្តរាគមន៍លេខ៦ មេរង អ.ធំស៊ើបការណ៍
១៩៨-នាយចំណាង	**នឿត ឌា**	អត្តលេខ ១០៣១៩០	កងពលតូចអន្តរាគមន៍លេខ៦ មេ អ.ធំ១ វ.តូច២៦២
១៩៩-នាយចំណាង	**ម៉ុំ ពាល់**	អត្តលេខ ០៦៤៧៦០	កងពលតូចអន្តរាគមន៍លេខ៦ មេ អ.ធំគាំទ្រ វ.តូច២៦២
២០០-នាយចំណាង	**ស៊្រូត ស៊ុំ**	អត្តលេខ ០៦៤៧១០	កងពលតូចអន្តរាគមន៍លេខ៦ មេរង អ.ធំគាំទ្រ វ.តូច២៦២
២០១-នាយចំណាង	**ចោន ឌួន**	អត្តលេខ ១៥៧០១៨	កងពលតូចអន្តរាគមន៍លេខ៦ មេបញ្ជាការរង វ.តូច ២៦៣
២០២-នាយចំណាង	**ឈួន នេខ**	អត្តលេខ ១៥៦៨១៩	កងពលតូចអន្តរាគមន៍លេខ៦ ជំនួយការហិរញ្ញវត្ថុ វរសេនាតូច២៦៤
២០៣-នាយចំណាង	**ម៉ឿន មាច**	អត្តលេខ ០៧០៨៦៤	កងពលតូចអន្តរាគមន៍លេខ៦ មេបញ្ជាការរង កងអនុសេនាធំកាំភ្លើងធំ
២០៤-នាយចំណាង	**ចាប ឌន់**	អត្តលេខ ១៥៦៩៣៣	កងពលតូចអន្តរាគមន៍លេខ៦ មេបញ្ជាការរង ឯអនុសេនាធំរថក្រោះ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៩១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនលោកជំទាវ លោក លោកស្រី ជាតំណាងស្ថានទូតអូស្ត្រាលី និងទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ (AusAID) ចំនួន ០៣ រូប ដែលបានរួមចំណែកក្នុងការកសាងទំនាក់ទំនងមិត្តភាពយ៉ាងល្អ បានផ្តល់ជំនួយបច្ចេកទេស និងជំនួយហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅប្រទេសកម្ពុជា ដូចមានរាយនាមខាងក្រោម :

- គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនចំពោះ :

១-លោកជំទាវ MARGARET ADAMSON ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា

- គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **សេនា** ជូនចំពោះ :

១-លោក LACHLAND PONTIFEX ទីប្រឹក្សាសហប្រតិបត្តិការអភិវឌ្ឍន៍ នៃទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ

២-លោកស្រី ARTHI PATEL លេខាទី១សហប្រតិបត្តិការអភិវឌ្ឍន៍ នៃទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៩៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១: តែងតាំងលោក **ឈុំ ឆុនលី** ជាសកលវិទ្យាធិការរង នៃសកលវិទ្យាល័យជាតិគ្រប់គ្រង នៃក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១០
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៨៩៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ ជូនលោក លោកស្រី ចំនួន០៣រូប ដែលមានស្នាដៃល្អលើវិស័យសុខាភិបាល ក្នុងការជួយដល់មន្ទីរពេទ្យកុមារជាតិ ផ្នែកជំនាញបច្ចេកទេស ដូចជាការគ្រប់គ្រងផ្នែកថែទាំអ្នកជម្ងឺ ការអប់រំ ការគ្រប់គ្រង ការចម្លងរោគ ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

១-លោកស្រី Tomiko Kusugawa
២-លោក Masaaki Kawamura
៣-លោកស្រី Saiko Igarashi

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៩៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនអង្គការ **JHP** ដែលបានផ្តល់ថវិកាចំនួន ១៩៣.១៧០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន ១០បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ និងធ្វើបង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ ជូនដល់សាលាគរុកោសល្យ និងវិក្រឹតការខេត្តបាត់ដំបង ស្ថិតនៅភូមិអូរខ្ជាយ សង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ MK

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

គណៈរដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩៥ អនក្រ.បក

អនុក្រឹត្យ

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនសមាគម **ASHIKITA Town & Ashikita International Exchange Association KUMAMOTO Prefecture JAPAN** ដែលបានផ្ដល់ថវិកាចំនួន ៤៩.៩០០ ដុល្លារអាមេរិក តាមរយៈអង្គការ **JHP** ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ សង់ពីបេតុង គ្រោងដំបូលដែក ជូនដល់សាលាបឋមសិក្សាស្វាយសុខោ ស្ថិតនៅភូមិស្វាយសុខោ សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១០

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩៦ .អនក្រ .បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យកុមារជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១០ ស្តីពីការប្រែក្លាយមន្ទីរពេទ្យ កុមារជាតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១ : ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យកុមារជាតិដូចមានរាយនាមខាងក្រោម ៖

១. លោកជំទាវ	**គ្រុយ លាងស៊ីម**	តំណាងក្រសួងសុខាភិបាល	ប្រធាន
២. ឯកឧត្តម	**ទេស សុខម៉េង**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៣. លោក	**វណ្ណា សំណាង**	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៤. លោកវេជ្ជបណ្ឌិត	**មី សំបូរ**	ឥស្សរជនមានចំណេះដឹង និងបទពិសោធខាងវិទ្យាសាស្ត្រសុខាភិបាល	សមាជិក
៥. លោក	**គឹម សាវុធ**	តំណាងសាលារាជធានីភ្នំពេញ	សមាជិក
៦. លោកសាស្ត្រាចារ្យ	**ឈួ អ៊ីម៉េង**	នាយកមន្ទីរពេទ្យកុមារជាតិ	នីតិសមាជិក
៧. លោកវេជ្ជបណ្ឌិត	**ភ្លាន់ យុវត្ថា**	តំណាងបុគ្គលិកមន្ទីរពេទ្យកុមារជាតិ	នីតិសមាជិក។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៧ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ចម្លងជូន ៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ: ០៤៤ / [illegible] / ២០១០

ក្រសួងសុខាភិបាល

លេខ: ០៥៦ [illegible]

ប្រកាសរួម
ស្តីពី
លក្ខខណ្ឌកាយសម្បទានិងសុខភាពប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ
រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស /រកម/ ១២០៦/០៣០ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកាតព្វកិច្ចយោធា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល

ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

- បានឃើញ អនុក្រឹត្យលេខ ៣១ អនក្រ. បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២០០ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ស្តីពី លក្ខខណ្ឌនិងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេលសម្រាប់យុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេស និងការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា
- តាមការចាំបាច់របស់ក្រសួងការពារជាតិ និងក្រសួងសុខាភិបាល

សម្រេច

ប្រការ ១.- ត្រូវបានកំណត់ប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធាប្រភេទទី១ ដែលមានលក្ខខណ្ឌកាយសម្បទា និងសុខភាពល្អគ្រប់គ្រាន ដូចខាងក្រោមៈ

កាយសម្បទាល្អ ប្រព័ន្ធសរសៃឈាម-បេះដូងល្អ ប្រព័ន្ធផ្លូវដង្ហើមល្អ ប្រព័ន្ធចក្ខុវិញ្ញាណល្អ ប្រព័ន្ធត្រចៀក-ច្រមុះ-បំពង់ក ល្អ ការវិភាគឈាម ការថតឆ្លុះគ្រប់ប្រភេទល្អ លទ្ធផលនៃការវិភាគទឹកនោមល្អ ការវិភាគសុខភាពផ្លូវចិត្តប្រក្រតី សុខភាពមាត់-ធ្មេញល្អ ប្រព័ន្ធបន្តពូជ ល្អប្រក្រតី ប្រព័ន្ធរំលាយអាហារល្អ និងប្រព័ន្ធអ័រម៉ូនល្អ។

ប្រការ២.- ត្រូវបានកំណត់ប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធាប្រភេទទី២ ដែលមានលក្ខខណ្ឌកាយសម្បទា និងសុខភាពមធ្យមដូចខាងក្រោមៈ

កាយសម្បទាមធ្យម មានជំងឺស្រួចស្រាវ ឬរ៉ាំរ៉ៃ មិនធ្ងន់ធ្ងរ អាចព្យាបាលជាមិនលើសពី៦ខែ ហើយជាក់ស្តែងមិនប៉ះពាល់ឬប៉ះពាល់តិចតួចដល់កម្លាំងពលកម្មនិងការហ្វឹកហ្វឺនដូចជា ករណីមានជំងឺភ្នែក ជំងឺត្រចៀក-ច្រមុះ-បំពង់ក ជំងឺប្រព័ន្ធផ្លូវដង្ហើម ជំងឺសរសៃឈាម-បេះដូង ជំងឺប្រព័ន្ធរំលាយអាហារ ជំងឺគ្រុនចាញ់កម្រិតស្រាល ជំងឺរបេងគ្រប់ប្រភេទកម្រិតស្រាល ជំងឺគ្រុនពោះវៀន ជំងឺសើស្បែក ជំងឺកាមរោគ ជំងឺរលាកប្រព័ន្ធទឹកនោមជំងឺប្រព័ន្ធអ័រម៉ូន ស្នាកស្នាមរបួសដែលមិនប៉ះពាល់ដល់ជីវភាពប្រចាំថ្ងៃ ជំងឺមាត់-ធ្មេញកម្រិតមធ្យម ជំងឺផ្លូវចិត្តកម្រិតមធ្យម ស្ត្រីកំពុងមានគភ៌ឬមានដុំប៉ុន្តែមិនមែនមហារីក និងអ្នកញៀនគ្រឿង

ញៀនកម្រិតស្រាលឬមធ្យម ។ ប្រជាពលរដ្ឋដែលមានសុខភាពប្រភេទទី២នេះ ត្រូវដាក់ឱ្យជាប់បម្រុង សម្រាប់ការជ្រើសរើសបំពេញបន្ថែមនៅពេលដែលប្រជាពលរដ្ឋប្រភេទទី១មានមិនគ្រប់គ្រាន់តាមតម្រូវការ ។

ប្រការ ៣.- ត្រូវបានកំណត់ប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធាប្រភេទទី ៣ដែលមានលក្ខខណ្ឌកាយសម្បទា និងសុខភាព មិនប្រក្រតី មិនត្រូវខ្នាត ឬមានជំងឺមិនអាចចូលបំពេញកាតព្វកិច្ចយោធាបាន ដូចខាងក្រោម:

កាយសម្បទាមិនប្រក្រតី មានស្ថានភាពជំងឺប្រចាំកាយរ៉ាំរ៉ៃធ្ងន់ធ្ងរដែលចាំបាច់ត្រូវការគ្រូពេទ្យព្យាបាល និងតាមដានជាប្រចាំ (ជំងឺត្រូវការព្យាបាលយូរអង្វែង)និងពុំអាចធ្វើការងារបានពេញលេញដូចជាករណីមានជំងឺខ្សោយតម្រងនោម គ្រួសក្នុងតម្រងនោម រលាកតម្រងនោមរ៉ាំរ៉ៃ ជំងឺបេះដូងគ្រប់ប្រភេទ ជំងឺសួតរ៉ាំរ៉ៃ ជំងឺហឺត ជំងឺរលាកក្រពះ-ពោះវៀនរ៉ាំរ៉ៃ ដំបៅក្រពះ-ពោះវៀន ជំងឺលើសឈាម ជំងឺឆ្កួតជ្រូក ជំងឺមហារីក គ្រប់ប្រភេទ ជំងឺព្រៀមលក្ខណៈវះកាត់ធំ ជំងឺទឹកនោមផ្អែម ជំងឺថ្លើមប្រភេទ B និង C ជំងឺស្ត្រីរ៉ាំរ៉ៃ ជំងឺវិកលចរិតស្រួចស្រាវឬរ៉ាំរ៉ៃនិងជំងឺផ្លូវចិត្តដទៃទៀតដែលប៉ះពាល់ដល់ការគិត អាកប្បកិរិយានិងមុខងារប្រចាំថ្ងៃ ស្ថានភាពទាំងឡាយដែលជាផលវិបាកនៃជំងឺគ្រុនស្វិតដៃជើង គ្រោះថ្នាក់ចរាចរធ្ងន់ធ្ងរ អ្នកញៀនគ្រឿងញៀនធ្ងន់ធ្ងរ ជំងឺប្រព័ន្ធប្រសាទនិងខួរក្បាល ជំងឺរបេងគ្រប់ប្រភេទសណ្ឋានធ្ងន់ធ្ងរ ពិការភាពផ្នែកប្រព័ន្ធប្រសាទបណ្តាលមកពីមូលហេតុគ្រប់ប្រភេទ ការបាត់បង់សមត្ថភាពពលកម្មដូចមានចែងក្នុងប្រកាសលេខ ១០៩ កប ប្រក ចុះថ្ងៃទី ១៦ ខែ មិថុនា ២០០៨ ស្តីពីតាវកាលិកហានិភ័យការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជំងឺដែលត្រូវធ្វើការស្តារនីតិសម្បទាផ្លូវចិត្ត-សង្គម ជំងឺមាត់-ធ្មេញធ្ងន់ធ្ងរដែលបាត់បង់មុខងារក្នុងការទំពារ និងបុគ្គលភេទទី៣ ។

ប្រការ ៤.- ប្រជាពលរដ្ឋដែលជាប់កាតព្វកិច្ចយោធាប្រភេទ ទី១ ទី ២ និង ទី ៣ ត្រូវពិនិត្យសុខភាពឡើងវិញក្នុងករណីចាំបាច់ ។

ប្រការ ៥.- លក្ខខណ្ឌលម្អិតកាយសម្បទា និងសុខភាពប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធាប្រភេទទី ១ ទី ២ និងទី៣មានចែងក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ។ គណៈកម្មការសុខាភិបាលសម្រាប់ត្រួតពិនិត្យសុខភាពប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធាមានសិទ្ធិស្នើសុំកែសម្រួលតារាងឧបសម្ព័ន្ធតាមការចាំបាច់ ។

ប្រការ ៦.- ការពិនិត្យសុខភាពត្រូវធ្វើនៅមន្ទីរពេទ្យថ្នាក់ជាតិ ឬមន្ទីរពេទ្យបង្អែកដែលនៅជិតបំផុតនៃមូលដ្ឋានប្រមូលផ្តុំប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធា។ រាល់ការចំណាយសម្រាប់ពិនិត្យសុខភាពប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធាជាបន្ទុករបស់ក្រសួងការពារជាតិ។

ប្រការ ៧.- គណៈកម្មការសុខាភិបាលសម្រាប់ត្រួតពិនិត្យសុខភាពពលរដ្ឋជាប់កាតព្វកិច្ចយោធាត្រូវរៀបចំ.../..

សំណុំឯកសារសម្រាប់ពិនិត្យ និងវាយតម្លៃសុខភាពប្រជាពលរដ្ឋម្នាក់ៗដែលជាប់កាតព្វកិច្ចយោធាឱ្យបានសមស្របតាមសភាពជាក់ស្តែងដោយផ្អែកលើមូលដ្ឋាននៃប្រកាសនេះ ។

ប្រការ ៨.- អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ នាយក នាយកដ្ឋានបុគ្គលិក មេបញ្ជាការយោធភូមិភាគ មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត ស្នងការនគរបាលរាជធានី ខេត្ត ប្រធានគណៈកម្មាធិការកាតព្វកិច្ចយោធាគ្រប់លំដាប់ថ្នាក់ ប្រធានគណៈកម្មការសុខាភិបាលសម្រាប់ត្រួតពិនិត្យសុខភាពពលរដ្ឋជាប់កាតព្វកិច្ចយោធា ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ ប្រធានអង្គភាពថ្នាក់កណ្តាល ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត និងបណ្តាស្ថាប័ន-អង្គភាពពាក់ព័ន្ធត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍.ទៀ-បាញ់

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ម៉ម-ប៊ុនហេង

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដូចប្រការ ៨
- ឯកសារ-កាលប្បវត្តិ

តារាងឧបសម្ព័ន្ធរបស់ប្រកាសរួម

ស្ដីពី

លក្ខខណ្ឌកាយសម្បទានិងសុខភាពប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធា

ក. ប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធាប្រភេទ ទី ១

១. កាយសម្បទា: ល្អ

ភេទ	កម្ពស់ ស.ម	ទម្ងន់ គក្រ	ទំហំទ្រូង ស.ម
ប្រុស	ចាប់ពី ១៥៨ ស.មឡើងទៅ	ចាប់ពី ៤៥ គ.ក្រឡើងទៅ	ចាប់ពី ៧០ស.មឡើងទៅ
ស្រី	ចាប់ពី ១៥២ ស.មឡើងទៅ	ចាប់ពី៤០គ.ក្រឡើងទៅ	មិនកំណត់

- អវៈយវៈ លូតលាស់ស្មើ
- ម្រាមដៃ ឬម្រាមជើងដែលលើស បានកាត់ចោលរួចហើយ និងមិនប៉ះពាល់ដល់សកម្មភាពប្រចាំថ្ងៃ

២. សុខភាព: ល្អ

ក. ប្រព័ន្ធចក្ខុវិញ្ញាណ (Ophtalmology)

លក្ខណៈ	ភ្នែកស្ដាំ	ភ្នែកទាំងពីរ
គំហើញ (Vision)	១០/១០	១៨ /១០
កន្ទុយថ្លែន (Pterygium)	កម្រិត ១រឺ២	កម្រិត ១រឺ២
ស្រទាប់គ្របកភ្នែកខាងក្នុង (Conjunctive)	ធម្មតា	ធម្មតា
កញ្ចក់ភ្នែក (Cornea)	ធម្មតា គ្មានសម្លាក	ធម្មតា គ្មានសម្លាក

ខ. សុខភាពមាត់-ធ្មេញ (Oral and Dental Health)

- ធ្មេញគ្រប់លក្ខណៈ

- ធ្មេញដង្កូវស៊ី កម្រិត ១-២ ពី ១ ទៅ ៥ ធ្មេញ ប៉ុន្តែមិនរំខានដល់ការទំពារ
- ដកឬបាត់ធ្មេញ១-២ ប៉ុន្តែមិនប៉ះពាល់ដល់ធ្មេញថ្គាម ហើយការទំពារនៅបំពេញមុខងារបាន ៩០%ឡើងទៅ។
- រលាកអញ្ចាញធ្មេញចន្លោះពី ៤-៥ ធ្មេញ គ្មានខ្ទុះ ប៉ុន្តែធ្មេញនៅរឹងមាំ

គ. ត្រចៀក-ច្រមុះ-បំពង់ក (Ear-Nose-Throat)

- ត្រចៀកស្តាប់ឮសងខាងពី ៤-៥ ម៉ែត្រ
- រលាកក្រដាសត្រចៀកប៉ុន្តែបានព្យាបាលជា មិនសើរើឡើងវិញក្នុងរយៈពេល ១ ឆ្នាំ

● ជំងឺដែលអាចព្យាបាលជាសះស្បើយដូចខាងក្រោម:

- រលាកច្រមុះសាមញ្ញ (Simple Rhinitis) មិនប៉ះពាល់ដល់ការដកដង្ហើម
- រលាកបំពង់កស្រួចស្រាវ (Acute Pharyngitis)
- ដុះសាច់បំពង់ក ប៉ុន្តែបានកាត់ចោលរួចហើយ
- រលាកបំពង់សំឡេងស្រួចស្រាវ (Acute Laryngitis)
- រលាកច្រមុះប៉ះពាល់ដល់ឆ្អឹងថ្ពាល់ទាំងសងខាងកម្រិតស្រាល

ឃ. ប្រព័ន្ធផ្លូវដង្ហើម

- ដង្ហើមចេញ-ចូលប្រក្រតី
- ទម្រង់ទ្រូងឆ្វេង-ស្តាំ ប៉ុន គ្នា (Left and Right chest is symmetric)
- លទ្ធផលថតសួត ធម្មតា

ង. ប្រព័ន្ធសរសៃឈាម-បេះដូង (Cardio-Vascular System)

- សម្ពាធឈាមនិងជីពចរក្នុងរង្វង់ធម្មតា
- ចង្វាក់បេះដូងល្អ ឬ អាចមានវិបត្តិចង្វាក់បេះដូងកម្រិតស្រាល (Mild heart Rhythm disorder)

ច. ប្រព័ន្ធរំលាយអាហារ **(Gastro-Intestinal System)**

- បំពង់អាហារ ក្រពះ និងពោះវៀនល្អ
- រលាកខ្នែងពោះវៀន និងបានព្យាបាលវះកាត់លទ្ធផលល្អ
- ពកសាច់ពោះវៀន Polyp និងបានវះកាត់ទទួលលទ្ធផលល្អ

ឆ. ប្រព័ន្ធទឹកមូត្រ-បន្តពូជ **(Uro-Genital System)**

- ស្បែកគ្របលិង្គ (Phimosis) មិនរំខានដល់ការបន្ទោរបង់ និងបានវះកាត់ទទួលបានលទ្ធផលល្អ
- ប្រមេះស្រួចស្រាវ (Acute Gonorrhea) និងជំងឺកាមរោគកម្រិតស្រាលដទៃទៀត ប៉ុន្តែបានព្យាបាលជា
- គ្មានជំងឺមហារីកសុដន់ ឬមហារីកប្រដាប់បន្តពូជ
- គ្មានគភ៌

ជ. ជំងឺសើស្បែក **(Dermatological Diseases)**

- ស្រែង (Trichophytis), ភ្លី (Pytiriasis Versiculor)
- ផ្សិតស្បែកកម្រិតស្រាល គ្មានផលវិបាក ទំហំមិនលើសប៉ុនបាតដៃ
- ផ្សិតពី ១-២ ក្រចកដៃ ប៉ុន្តែ គ្មានជំងឺលើស្បែក
- កមរមាស់នៅមួយកន្លែងប៉ុន្តែគ្មានផលវិបាក
- ស្លាកស្នាមសើស្បែកពីកំណើតគ្រប់ប្រភេទទំហំមិនលើស ៣ សម^2 មិននៅតំបន់ចំហ
- ខ្មៅពីកំណើត មិនប៉ះពាល់ដល់សម្ផស្សទំហំមិនលើសពី ៥សម^2
- បណ្តុំពកធម្មតានៅតំបន់មិនប៉ះពាល់ដល់សុខភាព ពលកម្ម ហ្វឹកហាត់ និងជីវភាពផ្សេងៗ
- ក្លូន (Hernia)ដែលវះកាត់បានទទួលបានលទ្ធផលល្អ មានសុវត្ថិភាពលើសពី ១ ឆ្នាំ

ស្លាកស្នាមរលាកគ្រប់ប្រភេទមានទំហំតូច បានព្យាបាលជា មិនប៉ះពាល់ដល់ការធ្វើចលនា ជីវភាព និង

ឈ. សុខភាពផ្លូវចិត្ត (Mental Health)

- អារម្មណ៍ល្អចំពោះខ្លួនឯងនិងអ្នកដទៃ (Good feeling to her/him self and others)
- ការគិតត្រឹមត្រូវ (Logical thinking)
- អាកប្បកិរិយាប្រក្រតី (Normal Behavior) ។ អាចមានទំនាស់ជាមួយគ្រួសារ មិត្តភ័ក្តិ តិចតួច (Mild Conflicts with family/Friends) ឬមានភាពតានតឹងផ្លូវចិត្ត ឬស្ត្រេសតិចតួច (Mild Stresses) ដោយសារមូលហេតុណាក៏ដោយ ប៉ុន្តែមិនប៉ះពាល់ ឬប៉ះពាល់ដល់ការងារតិចតួច ។

ញ. ការវិភាគឈាម និងការរាប់គ្រាប់ឈាម

- Hemogramme: ស្ថិតក្នុងសភាពធម្មតា
- Blood Biochemical test: ស្ថិតក្នុងរង្វង់ធម្មតា

ដ. តេស្ត ជំងឺកាមរោគ មេរោគហ៊ីវ និង ជំងឺថ្លើមប្រភេទ បេ និង សេ (Test of Venereology, HIV, Hepatitis B and C)

- VDRL : អវិជ្ជមាន
- Ag. HBS, HVC: អវិជ្ជមាន
- HIV : អវិជ្ជមាន ។ ក្នុងករណីវិជ្ជមានត្រូវចាត់បញ្ចូលក្នុងប្រភេទទី៣ (ការពិនិត្យរកមេរោគហ៊ីវត្រូវរក្សាការសម្ងាត់)

ឋ. ការវិភាគទឹកនោម (Urine Test) ស្ថិតក្នុងសភាពធម្មតា

__Pregnancy test:__ អវិជ្ជមាន

តារាងឧបសម្ព័ន្ធនៃប្រកាសរួមស្តីពីលក្ខខណ្ឌកាយសម្បទានិងសុខភាពប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធា

ខ. ប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធាប្រភេទ ទី ២

១. កាយសម្បទាមធ្យម (Medium Physical Conditions)

ភេទ	កម្ពស់ ស.ម	ទម្ងន់ គ.ក្រ	ទំហំទ្រូង ស.ម
ប្រុស	ចាប់ពី ១៥០ ស.ម ឡើងទៅ	ចាប់ពី ៤០ គ.ក្រ ឡើងទៅ	ចាប់ពី ៦៥ ស.មឡើងទៅ
ស្រី	ចាប់ពី១៥០ ស.ម ឡើងទៅ	ចាប់ពី ៣៧ ស.ម ឡើងទៅ	មិនកំណត់

- អវៈយវៈ លូតលាស់ស្មើ

២. សុខភាពមធ្យម (Medium Health) មានជំងឺដែលអាចព្យាបាលជាមិនលើសពី៦ខែ

ក. ជំងឺភ្នែក (Eye Diseases)

លក្ខខណៈ	ភ្នែកស្តាំ	ភ្នែកទាំងពីរ
គំហើញ (Vision)	ចាប់ពី៦ /១០ ឡើងទៅ	ចាប់ពី១៣ /១០ឡើងទៅ
កន្ទុយថ្លែន (Pterygium)	កម្រិត ៣.៤.៥	កម្រិត ៣.៤.៥
ស្រទាប់គ្របកភ្នែកខាងក្នុង (Conjonctive)	កំពុងរលាកកម្រិតស្រាល	កំពុងរលាកកម្រិតស្រាល
កញ្ចក់ភ្នែក (Cornea)	មានសម្លាកតូច	មានសម្លាកតូច

- រលាកពងគ្រាប់ភ្នែក (Trachoma)
- ប្រែងជ្រួកទៅរោមភ្នែក (Trichiasis)
- រលាកភ្នែក (Chronic Episclerite)
- រលាកបំពង់ទឹកភ្នែក (Lacriocystite)
- រលាកភ្នាស (Chronic Conjunctivitis)
- ភ្នែកស្រលៀង (Strabismus)/

តារាងឧបសម្ព័ន្ធនៃប្រកាសរួមស្តីពីលក្ខខណ្ឌកាយសម្បទានិងសុខភាពប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធា

- ដង់ទីពន្លឺ ជិត និង ឆ្ងាយ កម្រិតស្រាល (Myopia) និងជំងឺភ្នែកផ្សេងៗទៀតដែលមានកម្រិតស្រាល ។ ជំងឺភ្នែកទាំងនេះនឹងជាទៅវិញក្រោយ ការព្យាបាលរយៈពេលខ្លី ។

ខ. សុខភាពមាត់-ធ្មេញ (Oral and Dental Diseases)

- ដង្កូវស៊ីធ្មេញ ៤-៩ ធ្មេញ
- រលាកជើងធ្មេញ (Gingivitis)
- រលាកបណ្តូលធ្មេញ (Pulpitis)
- ផលវិបាកថ្គាមទាល់
- រលាក រលាត់ភ្នាសមាត់-អណ្តាត
- រលាកក្រពេញទឹកមាត់
- រលាកសន្លាក់ Tempero-Mandibular Diseases)
- ឆ្អឹងថ្គាមបាក់កម្រិតមធ្យម (Symphisair and Parasymphisair fracture, Median fracture, Horizontal Branch fracture, Angle fracture) និងជំងឺមាត់-ធ្មេញកម្រិតស្រាលឬមធ្យមផ្សេងៗទៀត

គ. ជំងឺត្រចៀក ច្រមុះ បំពង់ក (Diseases of Ear-Nose-Throat)

- ត្រចៀកស្តាប់ឮ ពី ០.៥ មែត្រ ទៅ ៣.៥ ម៉ែត្រ
- រលាកស្បែកត្រចៀកក្រៅ ស្រួចស្រាវ និងរ៉ាំរ៉ៃមិនប៉ះពាល់ដល់ការស្តាប់
- រហែកស្បែកត្រចៀក
- ស្បែកត្រចៀកក្រៅប្រែខុសពីធម្មតា
- រលាកត្រចៀកកណ្តាល
- រលាកឆ្អឹងគុម្ពត្រចៀក ថ្គាម (Mastoïditis)
- រលាកត្រចៀកក្នុង
- ច្រមុះ បំពង់កវៀច មិនប៉ះពាល់ដល់ការបញ្ចេញសំឡេង ឬប៉ះពាល់ កម្រិតស្រាល ឬមិនប៉ះពាល់ដល់ចលនាទ្រូង ទំហំទ្រូង
- រលាកប្រអប់ឆ្អឹងថ្ពាល់ (Maxillofacial Sinusitis)
- ហូរឈាមច្រមុះគ្មានមូលហេតុ និងមិនប៉ះពាល់ ឬប៉ះពាល់តិចតួចដល់សុខភាព (Epistaxia)

- រលាកបំពង់សំឡេង មិនប៉ះពាល់ដល់ការបញ្ចេញសំឡេង (Laryngitis)
- និយាយគ្រដិត ច្បាស់២-៣ពាក្យ (Stuturing) និងជំងឺបំពង់សំឡេងកម្រិតស្រាលផ្សេងៗទៀត ។

ឃ. សុខភាពផ្លូវចិត្ត ជំងឺផ្លូវចិត្ត និងជំងឺផ្លូវចិត្តដែលបណ្តាលមកពីការប្រើប្រាស់បំពានគ្រឿងញៀន (Mental Health, Mental Diseases and Mental Diseases due to Substance Abuses)

- ជំងឺថប់បារម្ភទូទៅ (Generalized Anxiety Disorder)
- ជំងឺធ្លាក់ទឹកចិត្តកម្រិតស្រាល (Mild Depressive Disorder)
- ជំងឺស្រឹតកម្រិតស្រាល (Panic Disorder)
- ជំងឺបាក់ស្បាតកម្រិតស្រាល (Mild Post Traumatic Stress Disorder)
- ជំងឺចិត្ត-កាយវិបល្លាស (Somatoform Disorder)
- ប្រតិកម្មផ្លូវចិត្តស្រួចស្រាវ (Acute Stress Reaction)
- វិបត្តិសម្របសម្រួល (Adjustment Disorder)
- ជំងឺថប់បារម្ភ និងភ័យខ្លាចកម្រិតស្រាល (Phobic Anxiety Disorder)

- អ្នកញៀនគ្រឿងញៀនដែលបានព្យាបាលផ្តាច់គ្រឿងញៀន បានស្តារនីតិសម្បទា និងមិនលាប់ឡើងវិញក្នុងរយៈពេល១ ឆ្នាំយ៉ាងតិច និងជំងឺផ្លូវចិត្តផ្សេងៗទៀត

ង. ជំងឺសរសៃប្រសាទ (Neurological Diseases)

- ប្រតិកម្មឆ្លើយតបសរសៃពួរ ឬរំញោចសរសៃពួរជាប់ឆ្អឹងនឹងឆ្អឹងកើនស្មើ មិនប៉ះពាល់ចលនា (Reflex)
- រលាកសរសៃប្រសាទមុខ Facial Neuritis (Central, Peripheral)
- ស្ពឹកសរសៃប្រសាទក្រៅ Paralysis, Neuralgia

កំណត់សម្គាល់: ការវិភាគឈាមគ្រប់ប្រភេទ និងការវិភាគទឹកនោម បើលទ្ធផលមិនប្រក្រតី ត្រូវចាត់ថ្នាក់ជាប្រភេទទី ២ ឬ ទី៣ និងត្រូវពិនិត្យឡើងវិញ នៅពេលជ្រើសរើសលើកក្រោយ ។

គ. ប្រជាពលរដ្ឋជាប់កាតព្វកិច្ចយោធាប្រភេទ ទី ៣

ក. កាយសម្បទាមិនត្រូវខ្នាត

ភេទ	កម្ពស់ ស.ម	ទម្ងន់ គ.ក្រ	ទំហំទ្រូង ស.ម
ប្រុស	ក្រោម ១៥០ ស.ម	ក្រោម ៤០ គ.ក្រ	ក្រោម ៦៥ ស.ម
ស្រី	ក្រោម ១៥០ ស.ម	ក្រោម ៣៧ គ.ក្រ	មិនកំណត់

ខ. សុខភាពមិនល្អ ត្រូវការព្យាបាលរយៈពេលយូរ

- ជំងឺហង់សិនគ្រប់ប្រភេទដែលមិនទាន់ព្យាបាលជា (Current Leprosis)
- ជំងឺជើងដំរីដោយសារព្រូន (Elephantiasis)
- ខ្សោយ ឬខូចតម្រងនោម (Renal Failure)
- គ ឬថ្លង់ពីកំណើតឬបណ្តាលមកពីផលវិបាកនៃជំងឺផ្សេងៗ
- រលាកសួតរ៉ាំរ៉ៃ
- ម្រេញនៅករ៉ាំរ៉ៃ មានហូរខ្ទុះ (Chronic Adenopathy with Pus complication)
- រលាកច្រមុះរ៉ាំរ៉ៃ និងប៉ះពាល់ដល់ការដកដង្ហើម និងហិតក្លិន
- រលាកបំពង់ករ៉ាំរ៉ៃ ក្អកច្រើន ពិបាកដកដង្ហើម
- ដុះសាច់បំពង់ក រ៉ាំរ៉ៃប៉ះពាល់ដល់ការដកដង្ហើមឧស្សាហ៍សើរើឡើងវិញ (Tonsillitis)
- រលាកលំពែងស្រួចស្រាវ សណ្ឋានរលួយមានហូរឈាម (Acute Pancreatitis with Hemorrhagic complication)
- សំឡេងស្អកបណ្តាលមកពីមានដុំពក (Palpiloma) ឬបណ្តាលមកពីរលាកសរសៃសំឡេង
- ពិការអវៈយវៈគ្រប់មូលហេតុ
- ជំងឺសន្លាក់មានស្ពឹកសាច់ដុំ ជំងឺរឹងសន្លាក់
- ជើងវែងខ្លីជាងគ្នា ៥ សមឡើងទៅ/.

- ស្ពឹក ឬស្លាប់មួយចំហៀងខ្លួន
- ដាច់ម្រាមដៃម្ខាង ពី៣ម្រាមឡើងទៅ ដាច់មេដៃម្ខាង
- រលាកខួរក្បាល រលាកស្រោមខួរ
- ជំងឺស្វាយខួរក្បាល (Cerebral Syphilis)
- របេងខួរក្បាល (Brain Tuberculosis)
- របេងស្រោមពោះ (Peritonitis Tuberculosis) របេងឆ្អឹងគ្រប់ប្រភេទ របេងប្រព័ន្ធទឹកមូត្រ និងប្រព័ន្ធបន្តពូជគ្រប់ប្រភេទ (Uro-Genital Tuberculosis)
- ជំងឺស្វាយកម្រិត ៣ (Syphilis Stage III)
- ជំងឺស្វិតសាច់ដុំធ្ងន់ធ្ងរ (Myopathy) ប៉ះពាល់ដល់ពលកម្ម
- ជំងឺស្វិតពងស្វាសទាំងសងខាងបណ្តាលមកពីជំងឺក្រឡទែន (Mump) ដាច់លិង្គ
- ជំងឺមហារីកគ្រប់សរីរាង្គ និងគ្រប់ប្រភេទ
- ជំងឺឆ្កួតជ្រូក (Epilepsy)
- ជំងឺក្រិនថ្លើម (Liver Cirrhosis)
- អណ្តើកវីកធំបណ្តាលមកពីជំងឺក្រិនថ្លើម (Splenomegalia due to Liver Cirrhosis)អណ្តើកវីកធំបណ្តាលមកពីជំងឺខ្សោយ បេះដូង (Splenomegalia due to heart failure) អណ្តើកវីកធំ ឬ ក្រិនរ៉ាំរ៉ៃ បូសអណ្តើក (Spleen Abscess)
- ផលវិបាកនៃជំងឺបូសថ្លើម (Liver Abscess with complication)
- គ្រួសបំពង់ប្រមាត់ធំ (Stones in Common bile duct)
- ពុកឆ្អឹងកងកធ្ងន់ធ្ងរ ពុកឆ្អឹងកងខ្នងធ្ងន់ធ្ងរ (Severe Spinal Osteoporosis)
- រលាកសរសៃឈាមក្រហមគ្រប់ប្រភេទ ជំងឺច្របូកច្របល់សរសៃឈាម (Raynaud)

- ជំងឺពកក (Basedow)
- ជំងឺពកធំរឹងសន្ទាក់ការ៉ាំរ៉ៃ (Chronic Goutre)
- Durhing, Pemphigus, Pemphigoide, Eczema កើតច្រើនកន្លែង
- ដុំសាច់ចុងពោះវៀនធំ និងពោះវៀនធំ (Recto-Colic Polyposis)
- ងងឹតភ្នែក (Blindness)
- ញ័រដៃជើង (Parkinsonian, Chorea, Athetose)
- ស្គមរីងរៃ (Cachexia)
- វៀចក ពិការ ក (Spinal/Cervical cord deformation)
- ពិការភាពសរីរាង្គពីកំណើត (Congenital Mal formation)
- ជំងឺវិកលចរិតគ្រប់ប្រភេទ (All Psychotic Diseases: Schizophrenia, Schizoaffective Disorder, Persistent Delusional Disorder, Bipolar Affective Disorder, Mania, Drug/Substance Induced Mental Disorders)
- ជំងឺធ្លាក់ទឹកចិត្តធ្ងន់ធ្ងរ (Severe Depressive Disorders)
- ជំងឺអូ ស៊ីឌី Obsessive Compulsive Disorder (OCD)
- ជំងឺផ្លូវចិត្តធ្ងន់ធ្ងរផ្សេងៗទៀត

សុខភាពមាត់-ធ្មេញ

- រលាកសន្លាក់ឆ្អឹងថ្គាមធ្ងន់ធ្ងរដែលប៉ះពាល់ការទំពារ
- ឆ្អឹងថ្គាមបាក់ (Coronoid Fracture)
- មាត់ឆែប ក្រអូមមាត់ឆែប

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៦៦ ប្រក កសក

ប្រកាស
ស្តីពី
ការធ្វើវិញ្ញាបនកម្មឃ្លាំងពូជកៅស៊ូ និងការធ្វើអាជីវកម្មរុក្ខសម្ភារកៅស៊ូ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក.ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៀរគ្រសាស្រ្តនិងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ

អាគារលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០

- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាម អនាម័យ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សម្រេច

ប្រការ ១ : ប្រកាសនេះមានគោលដៅដាក់បញ្ញត្តិ និងលក្ខខណ្ឌគតិយុត្តក្នុងការគ្រប់គ្រង នាំចេញនាំចូល ចែកចាយ រុក្ខសម្ភារកៅស៊ូ និងការធ្វើវិញ្ញាបនកម្មច្បារពូជកៅស៊ូនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២ : ប្រកាសនេះមានគោលបំណង ÷

- ធានានិរន្តរភាពក្នុងការអភិរក្សភាពត្រឹមត្រូវនៃក្លូនកៅស៊ូ
- ធានាការផ្គត់ផ្គង់មែកពូជនៃក្លូនកៅស៊ូដែលចេញពីច្បារពូជដែលបានទទួលស្គាល់ដោយវិទ្យាស្ថាន
- បង្កើនផលិតភាពដំណាំកៅស៊ូប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច
- ទប់ស្កាត់ការក្លែងបន្លំក្លូនកៅស៊ូ និងលុបបំបាត់ការធ្វើអាជីវកម្មផ្គត់ផ្គង់ក្លូនកៅស៊ូដែលគ្មានគុណភាព សេនេទិច
- ផ្តល់ទំនុកចិត្តដល់អ្នកដាំកៅស៊ូក្នុងការវិនិយោគអភិវឌ្ឍន៍ដំណាំកៅស៊ូ និងផលិតកម្មកៅស៊ូ ។

ប្រការ ៣ : វាក្យស័ព្ទគន្លឹះដែលប្រើនៅក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម ÷

- " វិញ្ញាបនកម្មច្បារពូជកៅស៊ូ " សំដៅដល់ការចេញវិញ្ញាបនបត្រច្បារពូជកៅស៊ូដោយវិទ្យាស្ថាន ស្រាវជ្រាវកៅស៊ូកម្ពុជា
- "ច្បារពូជកៅស៊ូ " សំដៅដល់កន្លែងផលិតមែកពូជកៅស៊ូ សម្រាប់យកភ្នែកទៅបំបៅ
- "មែកពូជកៅស៊ូ " សំដៅដល់មែកពូជ ដែលកាត់ចេញពីដើមពូជនៅក្នុងច្បារពូជកៅស៊ូ និងមានភ្នែក សុទ្ធល្អសម្រាប់យកទៅបំបៅ
- "ក្លូនកៅស៊ូ " សំដៅដល់ដើមកៅស៊ូដែលមានអត្តសញ្ញាណដូចដើមមេ ដែលបង្កើតឡើងតាមការ បន្តពូជដោយសរីរាង្គលូតលាស់ ឬដោយកោសិកា
- "កូនកៅស៊ូស៊ីដលីង" សំដៅដល់កូនកៅស៊ូដែលដាំដោយគ្រាប់មិនបានបំបៅ
- "រុក្ខសម្ភារកៅស៊ូ" សំដៅដល់គ្រាប់កៅស៊ូ កូនកៅស៊ូស៊ីដលីង កូនកៅស៊ូបំបៅ និងកំណាត់សរីរាង្គដើម កៅស៊ូ សម្រាប់យកទៅដាំ
- "វិទ្យាស្ថាន" សំដៅដល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- "ភ្នាក់ងារ" សំដៅដល់មន្ត្រីរបស់វិទ្យាស្ថានដែលបានចាត់តាំងឱ្យទៅបំពេញការងារត្រួតពិនិត្យនិង វាយតម្លៃច្បារពូជកៅស៊ូ

- "អនុសាសន៍ក្លូន" សំដៅដល់បញ្ជីថ្នាក់ក្លូនកៅស៊ូដែលណែនាំដោយវិទ្យាស្ថាន សម្រាប់រយៈពេលពីពីរទៅប្រាំឆ្នាំ ដោយផ្អែកលើលទ្ធផលនៃការពិសោធស្រាវជ្រាវរបស់វិទ្យាស្ថាន ។

ប្រការ ៤ : ក្នុងការគ្រប់គ្រង និងការធ្វើវិញ្ញាបនកម្មច្បារពូជកៅស៊ូ វិទ្យាស្ថានមានសមត្ថកិច្ច និងបំពេញមុខងារដូចខាងក្រោម ÷

- ធានានិរន្តរភាពនៃក្លូនកៅស៊ូប្រកបដោយគុណភាព សម្រាប់ផលិតកម្មកៅស៊ូនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមដានត្រួតពិនិត្យ និងណែនាំដល់ម្ចាស់ច្បារពូជកៅស៊ូនៅទូទាំងប្រទេសឱ្យអនុវត្តស្របតាមសេចក្តីណែនាំបច្ចេកទេស អំពីច្បារពូជកៅស៊ូរបស់វិទ្យាស្ថាន
- កំណត់អត្តសញ្ញាណក្លូនកៅស៊ូ
- វាយតម្លៃច្បារពូជកៅស៊ូ និងផ្តល់វិញ្ញាបនបត្រច្បារពូជកៅស៊ូ
- សម្របសម្រួលការនាំចេញ នាំចូលរុក្ខសម្ភារកៅស៊ូ
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលដែលសម្រេចបានជូនស្ថាប័នអាណាព្យាបាល ។

ប្រការ ៥ : វិទ្យាស្ថានអាចផ្តល់វិញ្ញាបនបត្រច្បារពូជកៅស៊ូចំពោះតែច្បារពូជកៅស៊ូទាំងឡាយណាដែលក្លូនកៅស៊ូមានឈ្មោះនៅក្នុងអនុសាសន៍ក្លូនរបស់វិទ្យាស្ថាន ឬជាក្លូនដែលមានការអនុញ្ញាតឱ្យនាំចូលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សម្រាប់ការសាកល្បង ស្រាវជ្រាវ ។

ច្បារពូជកៅស៊ូដែលធ្វើអាជីវកម្ម ផ្គត់ផ្គង់ ប្រើប្រាស់ ឬបែងចែកមែកពូជបាន លុះត្រាតែច្បារពូជនោះត្រូវបានត្រួតពិនិត្យនិងវាយតម្លៃដោយភ្នាក់ងារ និងមានវិញ្ញាបនបត្រច្បារពូជកៅស៊ូដែលចេញដោយវិទ្យាស្ថាន ។

ច្បារពូជកៅស៊ូត្រូវបានត្រួតពិនិត្យនិងវាយតម្លៃដើម្បីទទួលបានវិញ្ញាបនបត្រ លុះត្រា ÷

- មានចំនួនគល់យ៉ាងតិច ២០០ (ពីររយ) គល់ ក្នុងក្លូននីមួយៗ
- មានក្លូនសុទ្ធល្អ
- ក្លូននីមួយៗ ត្រូវដាំជាប្លុកដាច់ដោយឡែកពីគ្នា
- មិនមានដំណាំដទៃដាំឆ្លកជាមួយ ។

ប្រការ ៦ : វិញ្ញាបនបត្រច្បារពូជកៅស៊ូ មានសុពលភាពសម្រាប់រយៈពេល ០២ (ពីរ) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្រ ។ ម្ចាស់ច្បារពូជ ត្រូវដាក់ពាក្យសុំវិញ្ញាបនបត្រច្បារពូជកៅស៊ូឡើងវិញរយៈពេល ០២ (ពីរ) ខែ មុនផុតកំណត់ ។

ការផ្លាស់ប្តូរទីតាំង ការពង្រីកច្បារពូជបន្ថែម ឬការផ្ទេរសិទ្ធិគ្រប់គ្រងច្បារពូជដែលមានវិញ្ញាបនកម្ម ត្រូវសុំការអនុញ្ញាតជាមុនពីវិទ្យាស្ថាន ។

ប្រការ ៧ : រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កើតច្បារពូជកៅស៊ូ ត្រូវស្នើសុំវិញ្ញាបនបត្រច្បារពូជកៅស៊ូនៅវិទ្យាស្ថាន ។

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កើតច្បារពូជកៅស៊ូ ត្រូវមានជំនាញយ៉ាងទាបបំផុតត្រឹមថ្នាក់បឋមក្សេត្រសាស្ត្រ ឬ ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកដំណាំកៅស៊ូ ដោយមានសញ្ញាបត្រ ឬ វិញ្ញាបនបត្រ ។ ម្ចាស់ច្បារពូជត្រូវទទួលខុសត្រូវចំពោះមុខច្បាប់លើគ្រប់សកម្មភាពនៃច្បារពូជ និងអ្នកប្រើប្រាស់ ។

ប្រការ ៨ : ការស្នើសុំវិញ្ញាបនបត្រច្បារពូជកៅស៊ូ ត្រូវបំពេញសំណុំបែបបទ និងភ្ជាប់មកជាមួយនូវលិខិតដូចខាងក្រោម ÷

១- ពាក្យស្នើសុំវិញ្ញាបនបត្រច្បារពូជកៅស៊ូមានបិទតែមប្រើ "មានគំរូ" ០១ច្បាប់ ។

២- កិច្ចសន្យាស្តីពី ការស្នើសុំវិញ្ញាបនបត្រច្បារពូជកៅស៊ូ "មានគំរូ" ០១ច្បាប់ ។

៣- ប្រវត្តិរូបសង្ខេបរបស់អ្នកស្នើសុំ "មានគំរូ" ០១ច្បាប់ ។

៤- គំនូរប្លង់ច្បារពូជ ។

៥- លិខិតប្រគល់សិទ្ធិ ។

៦- សញ្ញាបត្រ ឬវិញ្ញាបនបត្រច្បាប់ចម្លង ចូលរួមវគ្គបណ្តុះបណ្តាលដំណាំកៅស៊ូ ។

ម្ចាស់ច្បារពូជ ត្រូវបញ្ជូនសំណុំបែបបទមកវិទ្យាស្ថាន ។ ក្រោយពេលទទួលបានពាក្យស្នើសុំ វិទ្យាស្ថានត្រូវចាត់ភ្នាក់ងារចុះធ្វើការត្រួតពិនិត្យនិងវាយតម្លៃផ្ទាល់នៅច្បារពូជ ។ នីតិវិធីដែលត្រូវត្រួតពិនិត្យនិងវាយតម្លៃមានដូចខាងក្រោម ÷

១- ភាពត្រឹមត្រូវនៃក្លូននីមួយៗ

- កិនភាគខាងក្រៅនៃក្លូននីមួយៗនៅគ្រប់គល់ដោយពិនិត្យមើលផ្ទាល់នឹងភ្នែក
- ក្នុងករណីសង្ស័យ ត្រូវយកសំណាកមកធ្វើការវិភាគនៅមន្ទីរពិសោធន៍ ។

២- ស្ថានភាពថែទាំ

- អនុវត្តតាមការណែនាំបច្ចេកទេសធ្វើច្បារពូជរបស់វិទ្យាស្ថាន ។

ការផ្តល់វិញ្ញាបនបត្រច្បារពូជ ត្រូវផ្អែកលើសលាកបត្រត្រួតពិនិត្យនិងវាយតម្លៃ ។

ប្រការ ៩ : រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលនាំចេញ នាំចូលវត្ថុសម្ភារកៅស៊ូ ទោះជាសម្រាប់ពិសោធន៍សាកល្បងត្រូវមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ការផ្ទេរសិទ្ធិទៅឱ្យបុគ្គលដទៃនូវលិខិតអនុញ្ញាតនាំចេញ នាំចូលវត្ថុសម្ភារកៅស៊ូ ត្រូវមានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ប្រការ ១០ : រាល់វត្ថុសម្ភារកៅស៊ូដែលធ្វើការនាំចេញ នាំចូល និងឆ្លងកាត់ ត្រូវមានវិញ្ញាបនបត្របញ្ជាក់ភូតគាមអនាម័យ និងវិញ្ញាបនបត្របញ្ជាក់ប្រភពដើមដែលផ្តល់ដោយភ្នាក់ងារមានសមត្ថកិច្ច ។

ប្រការ ១១ : រូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម ÷

- ព្រមានជាលាយល័ក្ខណ៍អក្សរ និងតម្រូវឱ្យធ្វើកិច្ចសន្យាកែតម្រូវ
- ព្យួរ ឬដកហូតវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត
- ក្នុងករណីមិនរាងចាល ឬប្រព្រឹត្តល្មើសធ្ងន់ធ្ងរ នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ១២ : រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានបង្កើតច្បារពូជកៅស៊ូនៅមុនពេលប្រកាសនេះចូលជាធរមាន និងកំពុងធ្វើអាជីវកម្មកូនកៅស៊ូនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានលិខិតអនុញ្ញាត ឬមានលិខិតអនុញ្ញាតក្រោមនីតិវិធីផ្សេងពីប្រកាសនេះ ត្រូវស្នើសុំវិញ្ញាបនបត្រច្បារពូជកៅស៊ូអនុលោមតាមបទប្បញ្ញត្តិនៃប្រកាសនេះ ក្នុងរយៈពេលមិនលើសពី ៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះចូលជាធរមាន ។

ប្រការ ១៣ : ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ១៤ : អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ នាយកខុទ្ទកាល័យ នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ជឹម សារុន

កន្លែងទទួល :
